ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៦៧៥៩ ឧស.បល.សដស

ថ្ងៃ សុក្រ ១២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ស្តីពីការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត មន្ត្រីរាជការឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រាប់ឆ្នាំ២០២០

**យោង** ៖ លិខិតលេខ ៥៧៤៥ មស.ក្រខ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការផ្តល់ផែនការក្របខណ្ឌជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០២០

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមជម្រាបជូនដំណឹងដល់សិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិលទាំងអស់ឱ្យបានជ្រាបថា៖ ក្រសួងឧស្សាហកម្ម និងសិប្បកម្មនឹងធ្វើការប្រឡងប្រជែងជ្រើសរើសចូលបម្រើការងារជាមន្ត្រីរាជការក្នុងក្របខណ្ឌក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រាប់ឆ្នាំ២០២០នេះ ចំនួន **៣០** កន្លែង សម្រាប់ក្របខណ្ឌប្រភេទ **ក** ដើម្បីបំពេញការងារនៅទីស្តីការក្រសួង និងមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ដូចខាងក្រោម៖

**១- លក្ខខណ្ឌជ្រើសរើស ៖**

១.១. បេក្ខជនដែលមានបំណងដាក់ពាក្យប្រឡងប្រជែងចូលក្នុងក្របខណ្ឌក្រសួងឧស្សាហកម្ម និងសិប្បកម្មត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅឬសញ្ញាបត្រសមមូល

១.២. បេក្ខជនទាំងពីរភេទ ដែលដាក់ពាក្យស្នើសុំចុះឈ្មោះប្រឡង ត្រូវមានសញ្ជាតិខ្មែរ និងមានអាយុស្របទៅតាមការកំណត់ដូចមានចែងខាងក្រោម (គិតដល់ឆ្នាំប្រឡង) ៖

- បេក្ខជនត្រូវមានអាយុច្រើនបំផុតត្រឹម **៣៥ឆ្នាំ** ករណីមានសញ្ញាបត្របរិញ្ញាបត្រ ឬសមមូល
- បេក្ខជនត្រូវមានអាយុច្រើនបំផុតត្រឹម **៤០ឆ្នាំ** ករណីមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល
- ត្រូវបានលើកលែងលក្ខខណ្ឌអាយុ ចំពោះបេក្ខជនជានិស្សិត ដែលមានសញ្ញាបត្របណ្ឌិតឡើងទៅ។

១.៣. បេក្ខជនទាំងអស់ ត្រូវមានចំណេះដឹងជាបឋមលើជំនាញកុំព្យូទ័រ (Microsoft Word & Excel) ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាត្រឹមត្រូវ។

១.៤. មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ។

១.៥. បេក្ខជនដែលដាក់ពាក្យសុំប្រឡងប្រជែងចូលបម្រើការងារនៅទីស្តីការក្រសួង ក៏ដូចជានៅតាមមន្ទីរឧស្សាកម្ម និងសិប្បកម្ម ត្រូវមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅរាជធានី-ខេត្តដែលខ្លួនបានចុះឈ្មោះប្រឡង។

១.៦. ការផ្តល់អាទិភាព និងលើកទឹកចិត្តចំពោះ៖

- បេក្ខជនជាជនពិការ ដែលមានសមត្ថភាពសមស្របអាចបម្រើការងារបាន
- បេក្ខជនជានារី
- បេក្ខជនជាមន្ត្រីជាប់កិច្ចសន្យា ដែលបានបម្រើការងារនៅតាមអង្គភាពនីមួយៗ ក្រោមឱវាទក្រសួង
- បេក្ខជនដែលមានសញ្ញាបត្រភាសាបរទេសយ៉ាងតិចចំនួន ២ ភាសាដូចជា អង់គ្លេស និងបារាំង ឬ អង់គ្លេស និងចិន ឬ អង់គ្លេស និងជប៉ុន (ហើយប្រើប្រាស់ជាផ្លូវការបាន)

១.៧. ចំពោះបេក្ខជនជាមន្ត្រីរាជការ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ និងត្រូវមានលិខិតអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងពីប្រធានក្រសួង ស្ថាប័នសាមី។ ក្រោយពេលប្រឡងជាប់ជាស្ថាពរ បេក្ខជនជាមន្ត្រីរាជការ ត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែមិនរក្សាមុខតំណែងជូនទេ។



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

**២- មុខជំនាញជ្រើសរើសសម្រាប់ការប្រឡង ៖**

1- គីមីវិទ្យា និងទេពកោសល្យគីមីចំណីអាហារ
2- សំណង់ស៊ីវិល
3- ព័ត៌មានវិទ្យា
4- នីតិសាស្ត្រ និងសេដ្ឋកិច្ច
5- គណនេយ្យ និងហិរញ្ញវត្ថុ
6- បច្ចេកវិទ្យាផ្នែកយន្តសាស្ត្រ និងមេកានិចក្នុងវិស័យឧស្សាហកម្ម

**៣- ការបែងចែកឱ្យទៅបម្រើការងារ ៖**

៣.១ សម្រាប់បម្រើការងារនៅ**ទីស្តីការក្រសួង** ចំនួន **១១ កន្លែង**

៣.២ សម្រាប់បម្រើការងារនៅតាម**មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត** ចំនួន **១៩ កន្លែង** ក្នុងនោះ៖

- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបន្ទាយមានជ័យ ចំនួន **១ កន្លែង**
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង ចំនួន **១ កន្លែង**
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពង់ឆ្នាំង ចំនួន **១ កន្លែង**
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពង់ធំ ចំនួន **៣ កន្លែង**
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពត ចំនួន **២ កន្លែង**
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកោះកុង ចំនួន **១ កន្លែង**
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រៃវែង ចំនួន **១ កន្លែង**
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តសៀមរាប ចំនួន **៣ កន្លែង**
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តតាកែវ ចំនួន **៥ កន្លែង**
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តត្បូងឃ្មុំ ចំនួន **១ កន្លែង ។**

**៤- កាលបរិច្ឆេទទទួលពាក្យ និងទីកន្លែងទទួលពាក្យសុំប្រឡង ៖**

- <u>កាលបរិច្ឆេទទទួលពាក្យ</u> : ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រៀងរាល់ពេលម៉ោងធ្វើការ
  + ពេលព្រឹកចាប់ពីម៉ោង ៖ ៧:៣០-១១:៣០នាទី
  + ពេលរសៀលចាប់ពីម៉ោង ៖ ១៤:៣០-១៧:០០នាទី ។
- <u>កាលបរិច្ឆេទឈប់ទទួលពាក្យ</u> : **ថ្ងៃសុក្រ ទី០៨ ខែឧសភា ឆ្នាំ២០២០** ត្រឹមវេលាម៉ោង ១៧: ០០នាទី ជាកាលបរិច្ឆេទចុងក្រោយ។
- <u>ទីកន្លែងទំនាក់ទំនង និងទទួលពាក្យ</u> :
  - ចំពោះបេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡងចូលបម្រើការងារនៅថ្នាក់រដ្ឋបាលកណ្តាល (ទីស្តីការក្រសួង) ត្រូវដាក់ពាក្យនៅលេខាធិការដ្ឋាននៃគណៈកម្មការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការរបស់ក្រសួង(នាយកដ្ឋានបុគ្គលិក)។
  - ចំពោះបេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡងចូលបម្រើការងារនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវដាក់ពាក្យនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ក្រោមការត្រួតពិនិត្យផ្ទៀងផ្ទាត់ដោយប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត។

**៥- សំណុំលិខិតសុំចុះឈ្មោះប្រឡង ៖**

| | |
|---|---|
| ១- ពាក្យសុំចុះឈ្មោះប្រឡង (មានគំរូស្រាប់) | ចំនួន ១ ច្បាប់ |
| ២- ជីវប្រវត្តិសង្ខេបមានបិទរូបថតថ្មី ( ៤ X ៦ ) (មានគំរូស្រាប់) | ចំនួន ១ ច្បាប់ |
| ៣- សលាកបត្រឯកត្តជន (មានគំរូស្រាប់) | ចំនួន ២ ច្បាប់ |
| ៤- រូបថតថ្មី ៤ X ៦ (ថតចំពីមុខ) | ចំនួន ២ សន្លឹក |
| ៥- បង្កាន់ដៃទទួលពាក្យសុំសិទ្ធិប្រឡង (មានគំរូស្រាប់) | ចំនួន ២ ច្បាប់ |
| ៦- កិច្ចសន្យាបម្រើការងារ (មានគំរូស្រាប់) | ចំនួន ១ ច្បាប់ |
| ៧- ច្បាប់ចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន ១ ច្បាប់ |

៨- លិខិតថ្កោលទោស ( ក្រោយពេលប្រឡងជាប់ ) ចំនួន ១ ច្បាប់
៩- លិខិតពិនិត្យសុខភាព ( ក្រោយពេលប្រឡងជាប់ ) ចំនួន ១ ច្បាប់
១០- លិខិតបញ្ជាក់ពិការភាព (ចំពោះបេក្ខភាពជាជនពិការ) ចំនួន ១ ច្បាប់
១១- សេចក្តីចម្លងសញ្ញាប័ត្រ (មធ្យមសិក្សាទុតិយភូមិ/ បរិញ្ញាបត្រ/ បរិញ្ញាបត្រជាន់ខ្ពស់/ បណ្ឌិត ឬ សញ្ញាបត្រសមមូល) ឬ លិខិតបញ្ជាក់ការសិក្សាដោយមានការបញ្ជាក់ ទទួលស្គាល់ជាផ្លូវការ ចំនួន ១ ច្បាប់។

**៦- វិញ្ញាសាប្រឡង ៖**

១- វិញ្ញាសាវប្បធម៌ទូទៅ *រយៈពេល ២ ម៉ោង*
២- វិញ្ញាសាភាសាអង់គ្លេសទូទៅ *រយៈពេល ១ ម៉ោង និង ៣០ នាទី*
៣- វិញ្ញាសាជំនាញបច្ចេកទេស ទាក់ទងនឹងមុខជំនាញ ដែលបេក្ខជនស្នើសុំចុះឈ្មោះប្រឡងដូចបានបញ្ជាក់ខាងលើ *រយៈពេល ២ ម៉ោង។*

**៧- កាលបរិច្ឆេទ និងមណ្ឌលប្រឡង ៖**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងជូនដំណឹងពេលក្រោយយ៉ាងយូរឱ្យបានមុនរយៈពេល **១ សប្តាហ៍** នៃកាលបរិច្ឆេទប្រឡង។ សូម **បេក្ខជន** តាមដានព័ត៌មាននៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម តាមអាសយដ្ឋានទំនាក់ទំនងដូចបានបញ្ជាក់ជូនខាងក្រោម។

**សេចក្តីបញ្ជាក់៖**

- **បេក្ខជន** ត្រូវសរសេរ និងបំពេញសំណុំលិខិតសុំចុះឈ្មោះប្រឡង ត្រូវមកដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែងចូលបម្រើការងារដោយខ្លួនឯងផ្ទាល់
- **បេក្ខជន** ត្រូវទៅធ្វើលិខិតបញ្ជាក់ពីសុខភាពនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងលិខិតថ្កោលទោសនៅក្រសួងយុត្តិធម៌ជាបន្ទាន់ ក្រោយពីការប្រឡងជាប់ជាស្ថាពរ
- ករណីរកឃើញអ្នកប្រឡងជំនួស បេក្ខជននឹងត្រូវលុបឈ្មោះចេញពីក្របខណ្ឌក្រសួងឧស្សាហកម្ម និងសិប្បកម្ម ហើយអ្នកមកប្រឡងជំនួស នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន
- ព័ត៌មានលម្អិត សូមមកទំនាក់ទំនងនៅនាយកដ្ឋានបុគ្គលិក ការិយាល័យបៀវត្សរ៍ និងនៅតាមមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត រៀងរាល់ម៉ោងធ្វើការ ឬចូលទៅកាន់គេហទំព័រwww.mih.gov.kh និង Facebook «នាយកដ្ឋានបុគ្គលិក ក្រសួងឧស្សាហកម្ម និងសិប្បកម្ម» ទូរស័ព្ទ លេខ ០២៣ ២១១ ៩៣៤
- គណៈកម្មការប្រឡងសុំរក្សាសិទ្ធិក្នុងការកែប្រែកាលបរិច្ឆេទនៃការប្រឡង ក្នុងករណីចាំបាច់
- សេចក្តីជូនដំណឹងនេះ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងចាត់ទុកជាការប្រញាប់

អាស្រ័យហេតុនេះ សូម សិស្ស និស្សិត មន្ត្រីរាជការ និងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការប្រឡង**

**គឹម ទូច**

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-គ្រប់អង្គភាពចំណុះក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-គ្រឹះស្ថានសិក្សា
*"ដើម្បីជួយផ្សព្វផ្សាយ"*
- ឯកសារ-កាលប្បវត្តិ